**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៥៦៤៧ ប្រក

# ប្រកាស
## ស្តីពី
## ការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុង ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ ២០១៩

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៩៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្តីពីការលើកលែងលក្ខខណ្ឌដោយដំឡើងកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល
- យោងលិខិតលេខ ១០៩៧ មស.ក្រខ ចុះថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ

# សម្រេច

**ប្រការ ១ .—**

បើកឱ្យមានការប្រឡងប្រជែងជ្រើសរើសបេក្ខជនជា សិស្ស-និស្សិត ឱ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៩ ចំនួន **២៣២ នាក់** ដើម្បីឱ្យទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ៖

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ **ចំនួន ៦៨ នាក់**
- ក្របខ័ណ្ឌមន្ត្រីក្រមការ **ចំនួន ៧០ នាក់**
- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល **ចំនួន ៩៤ នាក់**

| **ល.រ** | **អង្គភាព** | **ចំនួនក្របខ័ណ្ឌជ្រើសរើសសម្រាប់ឆ្នាំ ២០១៩** | | | **ចំនួនសរុប** |
|---|---|---|---|---|---|
| | | ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ | ក្របខ័ណ្ឌមន្ត្រីក្រមការ | ក្របខ័ណ្ឌលេខាធិការរដ្ឋបាល | |
| | **ក. រដ្ឋបាលថ្នាក់ជាតិ** | | | | |
| ១ | ទីស្តីការក្រសួងមហាផ្ទៃ | ១២ | ១២ | ១៦ | ៤០ |
| | **ខ. រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | |
| **១** | សាលារាជធានីភ្នំពេញ | ២ | ៣ | ៤ | **៩** |
| | - សាលាខណ្ឌកំបូល | ៥ | ៥ | ៧ | **១៧** |
| | - សាលាខណ្ឌបឹងកេងកង | ៥ | ៦ | ៧ | **១៨** |
| **២** | សាលាខេត្តព្រះសីហនុ | ២ | ២ | ២ | **៦** |
| | - សាលាក្រុងកោះរ៉ុង | ៤ | ៣ | ៥ | **១២** |
| **៣** | សាលាខេត្តពោធិ៍សាត់ | ១ | ០ | ២ | **៣** |
| | - សាលាស្រុកតាលោសែនជ័យ | ៤ | ៣ | ៥ | **១២** |
| **៤** | សាលាខេត្តកំពង់ធំ | ១ | ១ | ២ | **៤** |
| | - សាលាស្រុកតាំងគោក | ៤ | ៣ | ៥ | **១២** |
| **៥** | សាលាខេត្តកណ្តាល | ២ | ២ | ៧ | **១១** |
| **៦** | សាលាខេត្តសៀមរាប | ២ | ២ | ១ | **៥** |
| **៧** | សាលាខេត្តព្រៃវែង | ២ | ៤ | ៣ | **៩** |
| **៨** | សាលាខេត្តបាត់ដំបង | ២ | ៤ | ២ | **៨** |
| **៩** | សាលាខេត្តបន្ទាយមានជ័យ | ២ | ៣ | ៣ | **៨** |
| **១០** | សាលាខេត្តកំពង់ចាម | ២ | ២ | ៣ | **៧** |
| **១១** | សាលាខេត្តឧត្តរមានជ័យ | ២ | ១ | ២ | **៥** |
| **១២** | សាលាខេត្តកំពង់ស្ពឺ | ២ | ២ | ៣ | **៧** |
| **១៣** | សាលាខេត្តត្បូងឃ្មុំ | ២ | ២ | ២ | **៦** |
| **១៤** | សាលាខេត្តតាកែវ | ២ | ២ | [illegible] | **៦** |
| **១៥** | សាលាខេត្តស្វាយរៀង | ១ | ១ | ២ | **៤** |
| **១៦** | សាលាខេត្តកំពត | ១ | ១ | ២ | **៤** |
| **១៧** | សាលាខេត្តក្រចេះ | ១ | ២ | ២ | **៥** |

| | | | | | |
|---|---|---|---|---|---|
| ១៨ | សាលាខេត្តកំពង់ឆ្នាំង | ១ | ១ | ២ | ៤ |
| ១៩ | សាលាស្រុកបរិរក្សស្វាយសែនជ័យ ខេត្តស្ទឹងត្រែង | ៤ | ៣ | ៥ | ១២ |
| | សរុប | ៦៨ | ៧០ | ៩៤ | ២៣២ |

**ប្រការ ២ .—**

បេក្ខជនទាំងពីរភេទដែលមានសិទ្ធិសុំចុះឈ្មោះប្រឡងប្រជែងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**ក-លក្ខខណ្ឌនៃការជ្រើសរើស ៖**

១- មានសញ្ជាតិខ្មែរ

២- មានកាយសម្បទាគ្រប់គ្រាន់ មានសុខភាពល្អ។ ករណីបេក្ខជនជាជនពិការ សាមីខ្លួនត្រូវមានស្ថានភាពពិការភាពសមស្រប ដែលអាចបំពេញការងារបាន។

៣- មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ។

៤- ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣៥ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល និង ៤០ ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល។ បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

៥- ជនពិការ បេក្ខជនជាស្ត្រី និងបេក្ខជនដែលនៅតំបន់ដាច់ស្រយាល ត្រូវបានលើកទឹកចិត្ត និងផ្តល់ការយកចិត្តទុកដាក់នៅក្នុងការប្រឡងប្រជែងនេះ។

៦- បេក្ខជន ត្រូវមានសញ្ញាបត្រ៖

- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់** ៖ បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រតាមមុខជំនាញសំខាន់ៗ ដូចជា នីតិសាស្ត្រ សេដ្ឋកិច្ច គ្រប់គ្រង ហិរញ្ញវត្ថុ ស្ថាបត្យកម្ម ភាសាបរទេស ព័ត៌មានវិទ្យា និងជំនាញផ្សេងៗ ឬសញ្ញាបត្រសមមូល ។
- **ក្របខ័ណ្ឌមន្ត្រីក្រមការ** ៖ បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បូក២ (ពីរ) ឆ្នាំនៃការសិក្សាថ្នាក់បរិញ្ញាបត្រតាមមុខជំនាញដូចមានរៀបរាប់ខាងលើ ឬសញ្ញាបត្រសមមូល។
- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល** ៖ បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្រយ៉ាងទាបបំផុត មធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល ។

**ខ-សំណុំលិខិតដែលត្រូវបំពេញរួមមាន ៖**

១- ពាក្យសុំចុះឈ្មោះប្រឡង ........................................ ចំនួន ០១ ច្បាប់

២- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ.................. ចំនួន ០១ ច្បាប់

៣- សញ្ញាបត្របរិញ្ញាបត្រ និង/ឬ បរិញ្ញាបត្រជាន់ខ្ពស់ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ.. ចំនួន ០១ ច្បាប់

៤- ជីវប្រវត្តិមានបិទរូបថត ៤x៦ ........................................ ចំនួន ០១ ច្បាប់

៥- កិច្ចសន្យា........................................ ចំនួន ០១ ច្បាប់

៦- រូបថត ៤x៦........................................ ចំនួន ០៣សន្លឹក

៧- បង្កាន់ដៃទទួលពាក្យប្រឡង ........................................ ចំនួន ០១ ច្បាប់

៨- សលាកបត្រគ្រូពេទ្យ........................................ ចំនួន ០១ ច្បាប់

៩- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត................ ចំនួន ០១ ច្បាប់

១០- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (ច្បាប់ថតចម្លង)........................................ ចំនួន ០១ ច្បាប់

១១- លិខិតបញ្ជាក់កិរិយាមាយាទរបស់សាមីខ្លួន ចេញដោយអាជ្ញាធរមូលដ្ឋាន ..................... ចំនួន ០១ ច្បាប់

១២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ .................. ចំនួន ០១ ច្បាប់។

**ប្រការ ៣ .—**

វិញ្ញាសា និងថេរវេលា នៃការប្រឡងជ្រើសរើស ៖

- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់**

១. ជំនាញឯកទេស.................................................................... រយៈពេល ០១ ម៉ោង ៣០ នាទី

(នីតិរដ្ឋបាល គ្រប់គ្រង ឬកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ឬកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា)

២. ភាសាអង់គ្លេស .................................................................... រយៈពេល ០១ ម៉ោង ៣០ នាទី

(ការបកប្រែអត្ថបទ និងវេយ្យាករណ៍)

- **ក្របខ័ណ្ឌមន្ត្រីក្រមការ**

១. ជំនាញឯកទេស.................................................................... រយៈពេល ០១ ម៉ោង ៣០ នាទី

(នីតិរដ្ឋបាល គ្រប់គ្រង ឬកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅកម្ពុជា)

២. ភាសាអង់គ្លេស.................................................................... រយៈពេល ០១ ម៉ោង ៣០ នាទី

(ការបកប្រែអត្ថបទ និងវេយ្យាករណ៍)

- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល**

១. ចំណេះដឹងទូទៅ ចំណេះដឹងកិច្ចការរដ្ឋបាល និងគណិតវិទ្យា....... រយៈពេល ០១ ម៉ោង ៣០ នាទី

(កម្មវិធីសិក្សាថ្នាក់ទី ១០ ដល់ ថ្នាក់ទី ១២)

២. តែងសេចក្តី ឬការសរសេរលិខិតរដ្ឋបាល ................................ រយៈពេល ០១ ម៉ោង ៣០ នាទី

(តែងសេចក្តី : កម្មវិធីសិក្សាថ្នាក់ទី ១០ ដល់ ថ្នាក់ទី ១២)

**ប្រការ ៤ .—**

បេក្ខជនត្រូវយកពាក្យសុំចុះឈ្មោះប្រឡង និងត្រូវដាក់ពាក្យប្រឡងនៅតាមទីកន្លែងនីមួយៗដែលបានកំណត់ដូចខាងក្រោម៖

- នាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល : សម្រាប់បេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត : សម្រាប់បេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជ្រើសរើស។

**មណ្ឌលប្រឡង កាលបរិច្ឆេទទទួលពាក្យប្រឡង និងកាលបរិច្ឆេទប្រឡង :**

- **មណ្ឌលប្រឡងត្រូវបានកំណត់ឲ្យមានដូចខាងក្រោម :**

ក/- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ** កំណត់ឲ្យមាន ៦ មណ្ឌលប្រឡង រួមមាន៖

**១-មណ្ឌលប្រឡងរាជធានីភ្នំពេញ** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ និងខេត្តកណ្តាល។

**២-មណ្ឌលប្រឡងខេត្តកំពង់ចាម** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង។

**៣-មណ្ឌលប្រឡងខេត្តសៀមរាប** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ។

**៤- មណ្ឌលប្រឡងខេត្តបាត់ដំបង** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

**៥- មណ្ឌលប្រឡងខេត្តកំពត** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅខេត្តកំពត ខេត្តព្រះសីហនុ ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ។

**៦- មណ្ឌលប្រឡងខេត្តក្រចេះ** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

ខ/- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល** កំណត់ឲ្យមាន ១៨ មណ្ឌលប្រឡង ស្ថិតនៅសាលា រាជធានីភ្នំពេញ និង សាលាខេត្តទាំង ១៧ ដែលមានបេក្ខជនបានដាក់ពាក្យស្នើសុំទៅបម្រើការងារ។

កាលបរិច្ឆេទទទួលពាក្យប្រឡងចាប់ពីថ្ងៃជូនដំណឹង រហូតដល់ថ្ងៃ **សុក្រ ទី៣០ ខែសីហា ឆ្នាំ២០១៩** ។

កាលបរិច្ឆេទប្រឡងនៅថ្ងៃ **អាទិត្យ ទី២២ ខែកញ្ញា ឆ្នាំ ២០១៩** ។

## ប្រការ ៥ .–

ការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ត្រូវដឹកនាំ និងចាត់ចែងដោយគណៈកម្មការកណ្ដាលរៀបចំការប្រឡង និងគណៈកម្មការរៀបចំការប្រឡងរាជធានី-ខេត្ត ដែលសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

គណៈកម្មការកណ្ដាលរៀបចំការប្រឡង និងគណៈកម្មការរៀបចំការប្រឡងរាជធានី-ខេត្ត មានសិទ្ធិរៀងៗខ្លួនក្នុងការប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ និងត្រារបស់រដ្ឋបាលរាជធានី-ខេត្ត ។

## ប្រការ ៦ .–

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានកស្ដុភារ និងហិរញ្ញវត្ថុ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តពាក់ព័ន្ធ ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៩រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

***កន្លែងទទួល:***

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចប្រការ៦ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១៤៥០ សរក

# សេចក្ដីជូនដំណឹង

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់សិស្ស-និស្សិត ដែលមានបំណងចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃឲ្យបានជ្រាបថា ក្រសួងមហាផ្ទៃ សម្រេចបើកឲ្យមានការប្រឡងជ្រើសរើសសិស្ស-និស្សិតបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៩ ដើម្បីទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម ៖

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌជ្រើសរើសសម្រាប់ឆ្នាំ ២០១៩ | | | | ចំនួនសរុប |
|---|---|---|---|---|---|---|
| | | ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ | ក្របខ័ណ្ឌមន្ត្រីក្រមការ | ក្របខ័ណ្ឌលេខាធិការរដ្ឋបាល | | |
| | | | | លេខាធិការរដ្ឋបាល | ស្មៀនឃុំសង្កាត់ | |
| | **ក. រដ្ឋបាលថ្នាក់ជាតិ** | | | | | |
| ១ | ទីស្ដីការក្រសួងមហាផ្ទៃ | ១២ | ១២ | ១៦ | | ៤០ |
| | **ខ. រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | |
| **១** | **រាជធានីភ្នំពេញ** | **១២** | **១៤** | **១៨** | **១** | **៤៥** |
| ១/១ | សាលារាជធានីភ្នំពេញ | ២ | ៣ | ៤ | | ៩ |
| ១/២ | សាលាខណ្ឌកំបូល | ៥ | ៥ | ៧ | | ១៧ |
| ១/៣ | សាលាខណ្ឌបឹងកេងកង | ៥ | ៦ | ៧ | | ១៨ |
| ១/៤ | សាលាសង្កាត់បឹងរាំង (ខណ្ឌដូនពេញ) | | | | ១ | ១ |
| **២** | **ខេត្តព្រះសីហនុ** | **៦** | **៥** | **៧** | **១** | **១៩** |
| ២/១ | សាលាខេត្តព្រះសីហនុ | ២ | ២ | ២ | | ៦ |
| ២/២ | សាលាក្រុងកោះរ៉ុង | ៤ | ៣ | ៥ | | ១២ |
| ២/៣ | សាលាឃុំកំពេញ (ស្រុកស្ទឹងហាវ) | | | | ១ | ១ |
| **៣** | **ខេត្តកណ្ដាល** | **២** | **២** | **៧** | **៤** | **១៥** |
| ៣/១ | សាលាខេត្តកណ្ដាល | ២ | ២ | ៧ | | ១១ |
| ៣/២ | សាលាឃុំវិហារសួគ៌ (ស្រុកខ្សាច់កណ្ដាល) | | | | ១ | ១ |
| ៣/៣ | សាលាឃុំជ័យធំ (ស្រុកខ្សាច់កណ្ដាល) | | | | ១ | ១ |
| ៣/៤ | សាលាសង្កាត់កោះអន្លង់ចិន (ក្រុងតាខ្មៅ) | | | | ១ | ១ |
| ៣/៥ | សាលាឃុំតាលន់ (ស្រុកស្អាង) | | | | ១ | ១ |
| **៤** | **ខេត្តសៀមរាប** | **២** | **២** | **១** | **២** | **៧** |
| ៤/១ | សាលាខេត្តសៀមរាប | ២ | ២ | ១ | | ៥ |
| ៤/២ | សាលាឃុំសំបួរ (ស្រុកក្រឡាញ់) | | | | ១ | ១ |
| ៤/៣ | សាលាឃុំចាន់ស (ស្រុកសូទ្រនិគម) | | | | ១ | ១ |
| **៥** | **ខេត្តព្រៃវែង** | **២** | **៤** | **៣** | **៣** | **១២** |
| ៥/១ | សាលាខេត្តព្រៃវែង | ២ | ៤ | ៣ | | ៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥/២ | សាលាឃុំបឹងដោល (ស្រុកព្រះស្ដេច) | | | | ១ | ១ |
| ៥/៣ | សាលាឃុំគោកគ្វក (ស្រុកកំពង់ត្របែក) | | | | ១ | ១ |
| ៥/៤ | សាលាឃុំរំលេច (ស្រុកស៊ីធរកណ្ដាល) | | | | ១ | ១ |
| **៦** | **ខេត្តបាត់ដំបង** | **២** | **៤** | **២** | **៣** | **១១** |
| ៦/១ | សាលាខេត្តបាត់ដំបង | ២ | ៤ | ២ | | ៨ |
| ៦/២ | សាលាឃុំវាំងកេសី (ស្រុកសង្កែ) | | | | ១ | ១ |
| ៦/៣ | សាលាឃុំព្រៃតូច (ស្រុកមោងឫស្សី) | | | | ១ | ១ |
| ៦/៤ | សាលាឃុំស្ពុកប្រវឹក (ស្រុករតនមណ្ឌល) | | | | ១ | ១ |
| **៧** | **ខេត្តពោធិ៍សាត់** | **៥** | **៣** | **៧** | | **១៥** |
| ៧/១ | សាលាខេត្តពោធិ៍សាត់ | ១ | | ២ | | ៣ |
| ៧/២ | ស្រុកតាលោសែនជ័យ | ៤ | ៣ | ៥ | | ១២ |
| **៨** | **ខេត្តកំពង់ធំ** | **៥** | **៤** | **៧** | | **១៦** |
| ៨/១ | សាលាខេត្តកំពង់ធំ | ១ | ១ | ២ | | ៤ |
| ៨/២ | សាលាស្រុកតាំងគោក | ៤ | ៣ | ៥ | | ១២ |
| **៩** | **ខេត្តបន្ទាយមានជ័យ** | **២** | **៣** | **៣** | **៧** | **១៥** |
| ៩/១ | សាលាខេត្តបន្ទាយមានជ័យ | ២ | ៣ | ៣ | | ៨ |
| ៩/២ | សាលាសង្កាត់ម្កាក់ (ក្រុងសិរីសោភ័ណ) | | | | ១ | ១ |
| ៩/៣ | សាលាឃុំស្រះជីក (ស្រុកភ្នំស្រុក) | | | | ១ | ១ |
| ៩/៤ | សាលាឃុំណាំតៅ (ស្រុកភ្នំស្រុក) | | | | ១ | ១ |
| ៩/៥ | សាលាឃុំភ្នំលៀប (ស្រុកព្រះនេត្រព្រះ) | | | | ១ | ១ |
| ៩/៦ | សាលាឃុំគោករមៀត (ស្រុកថ្មពួក) | | | | ១ | ១ |
| ៩/៧ | សាលាឃុំបត់ត្រង់ (ស្រុកមង្គលបូរី) | | | | ១ | ១ |
| ៩/៨ | សាលាឃុំសំបួរ (ស្រុកមង្គលបូរី) | | | | ១ | ១ |
| **១០** | **ខេត្តកំពង់ចាម** | **២** | **២** | **៣** | **៣** | **១០** |
| ១០/១ | សាលាខេត្តកំពង់ចាម | ២ | ២ | ៣ | | ៧ |
| ១០/២ | សាលាឃុំស្ដៅ (ស្រុកកងមាស) | | | | ១ | ១ |
| ១០/៣ | សាលាឃុំអង្គរបាន (ស្រុកកងមាស) | | | | ១ | ១ |
| ១០/៤ | សាលាឃុំកងតាណឹង (ស្រុកកងមាស) | | | | ១ | ១ |
| **១១** | **ខេត្តស្ទឹងត្រែង** | **៤** | **៣** | **៥** | | **១២** |
| ១១/១ | សាលាស្រុកបុរីអូរស្វាយសែនជ័យ | ៤ | ៣ | ៥ | | ១២ |
| **១២** | **ខេត្តឧត្តរមានជ័យ** | **២** | **១** | **២** | **៣** | **៨** |
| ១២/១ | សាលាខេត្តឧត្តរមានជ័យ | ២ | ១ | ២ | | ៥ |
| ១២/២ | សាលាឃុំព្រះប្រឡាយ (ស្រុកត្រពាំងប្រាសាទ) | | | | | ១ |
| ១២/៣ | សាលាឃុំទំនប់ដាច់ (ស្រុកត្រពាំងប្រាសាទ) | | | | ១ | ១ |
| ១២/៤ | សាលាឃុំបាក់អន្លូង (ស្រុកត្រពាំងប្រាសាទ) | | | | ១ | ១ |
| **១៣** | **ខេត្តកំពង់ស្ពឺ** | **២** | **២** | **៣** | | **៧** |
| ១៣/១ | សាលាខេត្តកំពង់ស្ពឺ | ២ | ២ | ៣ | | ៧ |
| **១៤** | **ខេត្តត្បូងឃ្មុំ** | **២** | **២** | **២** | **១** | **៧** |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤/១ | សាលាខេត្តត្បូងឃ្មុំ | ២ | ២ | ២ | | ៦ |
| ១៤/២ | សាលាឃុំក្រូចឆ្មា (ស្រុកក្រូចឆ្មា) | | | | ១ | ១ |
| **១៥** | **ខេត្តតាកែវ** | **២** | **២** | | **២** | **៦** |
| ១៥/១ | សាលាខេត្តតាកែវ | ២ | ២ | | | ៤ |
| ១៥/២ | សាលាឃុំត្នោត (ស្រុកបាទី) | | | | ១ | ១ |
| ១៥/៣ | សាលាឃុំព្រៃរំដេង (ស្រុកគិរីវង់) | | | | ១ | ១ |
| **១៦** | **ខេត្តស្វាយរៀង** | **១** | **១** | **២** | **១** | **៥** |
| ១៦/១ | សាលាខេត្តស្វាយរៀង | ១ | ១ | ២ | | ៤ |
| ១៦/២ | សាលាឃុំសំឡី (ស្រុកកំពង់រោទិ៍) | | | | ១ | ១ |
| **១៧** | **ខេត្តកំពត** | **១** | **១** | **២** | **២** | **៦** |
| ១៧/១ | សាលាខេត្តកំពត | ១ | ១ | ២ | | ៤ |
| ១៧/២ | សាលាឃុំថ្មី (ស្រុកទឹកឈូ) | | | | ១ | ១ |
| ១៧/៣ | សាលាឃុំកោះតូច (ស្រុកទឹកឈូ) | | | | ១ | ១ |
| **១៨** | **ខេត្តក្រចេះ** | **១** | **២** | **២** | | **៥** |
| ១៨/១ | សាលាខេត្តក្រចេះ | ១ | ២ | ២ | | ៥ |
| **១៩** | **ខេត្តកំពង់ឆ្នាំង** | **១** | **១** | **២** | **២** | **៦** |
| ១៩/១ | សាលាខេត្តកំពង់ឆ្នាំង | ១ | ១ | ២ | | ៤ |
| ១៩/២ | សាលាឃុំសំរោងសែន (ស្រុកកំពង់លែង) | | | | ១ | ១ |
| ១៩/៣ | សាលាឃុំផ្លូវទូក (ស្រុកកំពង់លែង) | | | | ១ | ១ |
| **២០** | **ខេត្តកែប** | | | | **២** | **២** |
| ២០/១ | សាលាសង្កាត់កែប (ក្រុងកែប) | | | | ១ | ១ |
| ២០/២ | សាលាឃុំអង្កោល (ស្រុកដំណាក់ចង្អើរ) | | | | ១ | ១ |
| | សរុប | **៦៨** | **៧០** | **៩៤** | **៣៧** | **២៦៩** |

**មណ្ឌលប្រឡងត្រូវបានកំណត់ដូចខាងក្រោម ៖**

ក/- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ** កំណត់ឲ្យមាន ៦ មណ្ឌលប្រឡង :

**១- មណ្ឌលប្រឡងរាជធានីភ្នំពេញ** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ និងខេត្តកណ្ដាល

**២- មណ្ឌលប្រឡងខេត្តកំពង់ចាម** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង

**៣- មណ្ឌលប្រឡងខេត្តសៀមរាប** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ

**៤- មណ្ឌលប្រឡងខេត្តបាត់ដំបង** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ

**៥- មណ្ឌលប្រឡងខេត្តកំពត** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅខេត្តកំពត ខេត្តព្រះសីហនុ ខេត្តតាកែវ និង ខេត្តកំពង់ស្ពឺ

**៦-មណ្ឌលប្រឡងខេត្តក្រចេះ** : សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

ខ/- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល (លេខាធិការរដ្ឋបាល)** កំណត់ឲ្យមាន ១៨ មណ្ឌលប្រឡង ស្ថិតនៅសាលារាជធានីភ្នំពេញ និងសាលាខេត្តទាំង ១៧ ដែលមានបេក្ខជនបានដាក់ពាក្យស្នើសុំទៅបម្រើការងារ។

គ/- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល (ស្មៀនឃុំសង្កាត់)** កំណត់ឲ្យមាន ១៤ មណ្ឌលប្រឡង ស្ថិតនៅសាលារាជធានីភ្នំពេញ និងសាលាខេត្តទាំង ១៣ ដែលមានជ្រើសរើសស្មៀនឃុំសង្កាត់។ ដោយឡែកចំពោះបេក្ខជនដែលចូលរួមប្រឡងជាស្មៀនឃុំសង្កាត់នៅខេត្តកែប ត្រូវទៅប្រឡងនៅមណ្ឌលប្រឡងខេត្តកំពត។

បេក្ខជនដែលមានបំណងចូលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ត្រូវទៅដាក់ពាក្យសុំចុះឈ្មោះដើម្បីចូលរួមប្រឡងប្រជែងនៅការិយាល័យក្របខ័ណ្ឌ នាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ។

បេក្ខជនដែលមានបំណងចូលបម្រើការងារនៅសាលារាជធានី-ខេត្ត សាលាក្រុង ស្រុក ខណ្ឌ និងសាលាឃុំសង្កាត់ ត្រូវទៅដាក់ពាក្យសុំចុះឈ្មោះនៅតាមសាលារាជធានីភ្នំពេញ និងសាលាខេត្តសាមី នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ម៉ោង ១៧ : ០០ នាទី នាថ្ងៃសុក្រ ទី៣០ ខែសីហា ឆ្នាំ២០១៩ ជាកាលបរិច្ឆេទកំណត់ចុងក្រោយ** ។

កាលបរិច្ឆេទប្រឡង គឺនៅថ្ងៃ **អាទិត្យ ទី២២ ខែកញ្ញា ឆ្នាំ២០១៩** ។

ព័ត៌មានលំអិតផ្សេងៗទៀត សូមអញ្ជើញទាក់ទងផ្ទាល់នៅតាមការិយាល័យទទួលពាក្យសុំចុះឈ្មោះប្រឡងនៅតាមទីកន្លែងដែលបានកំណត់ នៅរៀងរាល់ម៉ោងធ្វើការ ។

**ថ្ងៃ** [illegible] **ខែ** [illegible] **ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣**

**រាជធានីភ្នំពេញ ថ្ងៃទី** ២៦ **ខែ** សីហា **ឆ្នាំ២០១៩**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ក្រសួងមុខងារសាធារណៈ
  (ដើម្បីជូនជ្រាប)
- សាលារាជធានី និងគ្រប់សាលាខេត្ត ពាក់ព័ន្ធ
  (ដើម្បីផ្សព្វផ្សាយ និងអនុវត្តន៍)
- ឯកសារ - កាលប្បវត្តិ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ២៥៧៧/១៩ អរបរ

# បទបញ្ញត្តិ
## សម្រាប់បេក្ខជនប្រឡងជ្រើសរើសបញ្ចូលក្នុង
## ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ
## សម័យប្រឡង ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងវិន័យនៅក្នុងពេលប្រឡងឲ្យប្រព្រឹត្តទៅបានល្អប្រសើរ បេក្ខជនត្រូវគោរពដាច់ខាតតាមបទប្បញ្ញត្តិនៃការប្រឡងដូចខាងក្រោម ៖

១. <u>ប្រការដែលបេក្ខជនត្រូវអនុវត្ត</u> :
- ត្រូវមកដល់មណ្ឌលប្រឡង មុនចាប់ផ្តើមដំណើរការប្រឡងរយៈពេល ១៥ នាទី
- ត្រូវស្លៀកសំលៀកបំពាក់សមរម្យ
- ត្រូវយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតសំគាល់ខ្លួន
- ត្រូវយកមកជាមួយនូវបង្កាន់ដៃទទួលពាក្យប្រឡង
- ត្រូវអនុវត្តតាមការណែនាំរបស់មេប្រយោគ និងអនុរក្ស
- រក្សារបៀបរៀបរយនៅក្នុងពេលប្រឡង
- ត្រូវប្រើប៊ិចដែលមានទឹកពណ៌ខៀវ
- ក្នុងពេលប្រឡងត្រូវរក្សាការស្ងៀមស្ងាត់ ។

២. <u>ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត</u> :
- មិនត្រូវលួចចម្លង ឬមានបំណងលួចចម្លង
- មិនត្រូវពិភាក្សា ឬចម្លងគ្នាឡើយ
- មិនត្រូវយកអាវុធជាតិផ្ទុះចូលក្នុងមណ្ឌលប្រឡងឡើយ
- **ហាមយកតាម និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងគ្រប់ប្រភេទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទដែលអាចផ្ទុកឯកសារបាន ចូលក្នុងបន្ទប់ប្រឡង។ ក្នុងករណីមេប្រយោគ ឬ អនុរក្សឆែករកឃើញ បេក្ខជននឹងត្រូវបណ្តេញចេញពីបន្ទប់ប្រឡង។**
- មិនត្រូវឲ្យអ្នកដទៃប្រឡងជំនួស ឬសរសេរកិច្ចការជំនួសនៅលើសន្លឹកកិច្ចការរបស់ខ្លួន
- មិនត្រូវគូសសញ្ញាសំគាល់នៅលើសន្លឹកកិច្ចការ
- មិនត្រូវធ្វើសកម្មភាពណាដែលនាំឲ្យចលាចលក្នុងមណ្ឌលប្រឡង
- ហាមដាច់ខាតចំពោះការសេពគ្រឿងស្រវឹង និងជក់បារីនៅក្នុងបរិវេណមណ្ឌលប្រឡង ។

**រាល់ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិខាងលើ បេក្ខជនត្រូវប្រឈមនឹងការបញ្ឈប់មិនឲ្យប្រឡង ហើយសន្លឹកកិច្ចការរបស់បេក្ខជននោះនឹងត្រូវបានពិន្ទុសូន្យ និងទទួលកម្រិតវិន័យផ្សេងៗទៀតដែលត្រូវបានកំណត់ដោយគណៈកម្មការកណ្តាលរៀបចំការប្រឡង ។**

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៩

**អគ្គនាយក និងជា**
**អនុប្រធានគណៈកម្មការកណ្តាលរៀបចំការប្រឡង**

ប្រាក់ សំអឿន